ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ
# រយៈពេល ៥ ឆ្នាំ ២០១៤~២០១៨

ត្រូវបានអនុម័ត

ដោយក្រសួងអភិវឌ្ឍន៍ជនបទ នៅថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៤

# អារម្ភកថា

ដោយកម្ពុជាបានទទួលនូវកុសលពីនយោបាយឈ្នះ ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ចេញ និងដឹកនាំអនុវត្តប្រកបដោយជោគជ័យតាំងពីចុងឆ្នាំ១៩៩៨ ហើយបាននិងកំពុងគ្រប់ដណ្តប់ដោយសុខសន្តិភាព ស្ថិរភាពនយោបាយ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ស្ថិរភាពហិរញ្ញវត្ថុ កម្ពុជាបានសម្រេចនូវជោគជ័យជាបន្តបន្ទាប់ក្នុងការអភិវឌ្ឍប្រទេសក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រត្រីកោណ បន្ទាប់មក យុទ្ធសាស្ត្រចតុកោណរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**។ ក្នុងបរិការណ៍នេះ កម្ពុជា បាននិងកំពុងទទួលបាននូវវឌ្ឍនភាព និងកាលានុវត្តភាពថ្មីៗ ក្នុងការអភិវឌ្ឍលើគ្រប់វិស័យទាំងនៅតំបន់ទីក្រុង និងជនបទ ជាអាទិ៍រួមមាន ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងអរូបវ័ន្តទាំងផ្នែករឹង និងផ្នែកទន់ ការអភិវឌ្ឍធនធានមនុស្ស បណ្តាញផ្លូវជនបទ ស្ពានសាលារៀន មន្ទីរពេទ្យ ផ្សារជនបទ និងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ ។ល។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បាននិងកំពុងខិតខំប្រឹងប្រែងបន្តកសាងប្រទេសកម្ពុជាមួយប្រកបដោយឯករាជ្យ សន្តិភាព ស្ថិរភាពនយោបាយ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការជំរុញកំណើនសេដ្ឋកិច្ចសំដៅបង្កើនកម្រិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង ជាពិសេស កាត់បន្ថយគម្លាតរវាងប្រជាជនដែលរស់នៅទីក្រុង និងជនបទ។

ពិតមែនតែគម្លាតរវាងអ្នកមាន និងអ្នកមិនទាន់មាន ត្រូវបានរួមក្តោបជាងមុនក៏ដោយ ក៏កម្ពុជាយើងត្រូវប្រឈមមុខនឹងបញ្ហាប្រឈមធំៗ ដែលតម្រូវឱ្យក្រសួងអភិវឌ្ឍន៍ជនបទជាអ្នកនាំមុខក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាលបន្តកំណត់នយោបាយយុទ្ធសាស្ត្រ ផែនការសកម្មភាព និងកិច្ចដំណើរការដើម្បីជំនះលើបញ្ហាប្រឈមទាំងនោះ ពីព្រោះបញ្ហាប្រឈមទាំងនោះស្ថិតនៅជនបទ។ នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ជាសេនាធិការផ្ទាល់របស់ក្រសួងអភិវឌ្ឍន៍ជនបទ ហើយដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជនបទនៅកម្ពុជា តាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទរយៈពេល ៥ឆ្នាំ ២០១៤-២០១៨ ដែលបានរៀបចំឡើងជាឯកសារយោង និងតម្រង់ទិសសម្រាប់ការអនុវត្តឱ្យសម្រេចបានតាមគោលដៅ គោលបំណង និងសកម្មភាពទាំងឡាយ ដែលគ្រោងអនុវត្តន៍ក្នុងរយៈពេល ៥ឆ្នាំ ខាងមុខ។

ផែនការយុទ្ធសាស្ត្រនេះ រៀបចំឡើង ដោយផ្តោតទៅលើការងារស្នូលចំនួន ៤ គឺការងារឥណទានជនបទ ការងារសហគ្រាសខ្នាតមីក្រូ និងខ្នាតតូច ការងាររកទីផ្សារ និងការអភិវឌ្ឍជនបទតាមរយៈវិធីសាស្ត្រចលនាភូមិថ្មី។ ផែនការនេះ ក៏បានបង្ហាញពីយុទ្ធសាស្ត្រគន្លឹះក្នុងការពង្រឹងសមត្ថភាពមន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាភ្នាក់ងារផ្តល់សេវាជូនប្រជាពលរដ្ឋនៅជនបទ ស្របតាមគោលការណ៍ នីតិវិធី និងឯកសារគតិយុត្តនានាដែលរៀបចំឡើងដោយនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ។ ទន្ទឹមនឹងនេះ នាយកដ្ឋាននឹងរៀបចំនូវឯកសារមូលដ្ឋានគតិយុត្តចាំបាច់មួយចំនួនបន្ថែម ដើម្បីគាំទ្រ និងពង្រឹងប្រព័ន្ធប្រតិបត្តិការក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋនៅជនបទឱ្យកាន់តែល្អប្រសើរឡើង ស្របតាម

ស្ថានភាពសេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់ស្តែង។ ផែនការនេះ ក៏មានចែងពីយុទ្ធសាស្ត្រស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញប្បទាន ព្រមទាំងយុទ្ធសាស្ត្រពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃ ដើម្បីធានាឱ្យការអនុវត្តប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពនិង ប្រសិទ្ធិផលខ្ពស់។

ក្រសួងអភិវឌ្ឍន៍ជនបទ ប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ឱ្យសម្រេចបានជោគជ័យតាមផែនការដែលបានគ្រោងទុក និងសូមអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ជាអាទិ៍ ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការជាតិ និងអន្តរជាតិ វិស័យឯកជន សហគមន៍ជនបទ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ ចូលរួមសហប្រតិបត្តិការ និងជួយគាំទ្រទាំងបច្ចេកទេស និងហិរញ្ញប្បទាន ដើម្បីសម្រេចឱ្យបាននូវគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ជាពិសេស បង្រួមគម្លាតរវាងជីវភាពប្រជាជនដែលរស់នៅទីក្រុង និងជនបទ តាមរយៈការជំរុញកំណើនសេដ្ឋកិច្ចជនបទ ដើម្បីបង្កើតបរិយាកាសសុខដុមរមណីយកម្ម ប្រកបដោយវឌ្ឍនភាព និងវិបុលភាពនៅក្នុងតំបន់ជនបទ។

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែ មីនា ឆ្នាំ ២០១៤

រដ្ឋមន្ត្រី

ជា សុផារ៉ា

# មាតិកា


| | ទំព័រ |
|---|---|
| ១. សេចក្តីផ្តើម | ១ |
| ២. ចក្ខុវិស័យ | ២ |
| ៣. គោលបំណង | ២ |
| ៤. យុទ្ធសាស្ត្រសំខាន់ៗ | ៣ |
| ៤.១. ការពង្រឹងសមត្ថភាពមន្ត្រី | ៣ |
| ៤.២. ការសិក្សាស្រាវជ្រាវស្ថានភាពសេដ្ឋកិច្ចសង្គមជនបទ | ៣ |
| ៤.៣. ការរៀបចំឯកសារគោលការណ៍ នីតិវិធី និងឯកសារគតិយុត្តតាមវិស័យ | ៤ |
| ១. ការងារឥណទាន | ៤ |
| ២. ការងារសហគ្រាសខ្នាតតូច | ៥ |
| ៣. ការងារទីផ្សារជនបទ | ៦ |
| ៤.៤. ពង្រឹងប្រព័ន្ធប្រតិបត្តិការក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ | ៧ |
| ១. ផ្នែកឥណទានជនបទ | ៧ |
| ២. ផ្នែកសហគ្រាសខ្នាតតូច | ៧ |
| ៣. ផ្នែកទីផ្សារជនបទ | ៨ |
| ៤.៥.រៀបចំសម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រចលនាភូមិថ្មី | ៩ |
| ៤.៦. ការស្វែងរកហិរញ្ញប្បទាន និងជំនួយបច្ចេកទេស | ១០ |
| ៤.៧. ពង្រឹងការតាមដាន និងវាយតម្លៃ | ១០ |
| ៥.តារាងផែនការសកម្មភាព | ១១ |
| ៦. សេចក្តីសន្និដ្ឋាន | ១៩ |

# ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ រយៈពេល ៥ ឆ្នាំ ២០១៤ - ២០១៨

## ១. សេចក្តីផ្តើម

បច្ចុប្បន្នកម្ពុជាបាន និងកំពុងមានការរីកចម្រើនលូតលាស់លើគ្រប់វិស័យអាស្រ័យដោយមនុញ្ញផល ដែលបានមកពីសុខសន្តិភាព ស្ថិរភាពនយោបាយ និងកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈររបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមកិច្ចដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានបន្តបេសកកម្មស្តារ និងអភិវឌ្ឍប្រទេសជាតិ ដោយបានដាក់ចេញនូវចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រនានាក្នុងការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងអរូបវ័ន្ត ទាំងនៅតំបន់ទីក្រុង និងជនបទ ជាអាទិ៍ ការអភិវឌ្ឍធនធានមនុស្ស បណ្តាញផ្លូវជនបទ ស្ពាន សាលារៀន មន្ទីរពេទ្យ ផ្សារ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជនបទ។ល។ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បាន និងកំពុងខិតខំប្រឹងប្រែងបន្តកសាងប្រទេសកម្ពុជាមួយ ប្រកបដោយឯករាជ្យ សន្តិភាព ស្ថិរភាពនយោបាយ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេសបានល្អប្រសើរឡើង ជាពិសេសគឺផ្តោតការយកចិត្តទុកដាក់ដល់ជីវភាពរបស់ប្រជាពលរដ្ឋនៅជនបទ។

ក្នុងនាមជាក្រសួងអាទិភាពរបស់រាជរដ្ឋាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ បានចូលរួមចំណែកយ៉ាងសកម្មក្នុងការងារអភិវឌ្ឍន៍ជនបទ សំដៅជំរុញកំណើនសេដ្ឋកិច្ចនៅជនបទ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ និងបង្រួមគម្លាតរវាងទីក្រុង និងជនបទ ស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៥ នៃរដ្ឋសភា។

ឆ្លើយតបទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការ ជំរុញកំណើនសេដ្ឋកិច្ចជនបទក្នុងព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកតាមតួនាទី និងភារកិច្ចរបស់ខ្លួនតាមរយៈកម្មវិធីឥណទានជនបទ បំផុសនិងលើកទឹកចិត្តឲ្យបង្កើតជាសហគ្រាសខ្នាតមីក្រូ និងខ្នាតតូចនៅទីជនបទជួយស្វែងរកទីផ្សារសម្រាប់ដោះដូរផលិតផល និងបង្កើតបណ្តាញទំនាក់ទំនងរវាងផលិតករ និងទីផ្សារផលិតផល។ ទន្ទឹមនឹងនេះ ដើម្បីជំរុញឲ្យដំណើរការនៃការងារអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងសមស្របទៅនឹងលក្ខខណ្ឌជាក់ស្តែងតាមតំបន់ ឬរាជធានី ខេត្ត និងក្រោមបរិបទនៃកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាចរន្តសកលភាវូបនីយកម្ម និងទីផ្សារសេរី ចាំបាច់ត្រូវទាមទារឲ្យមានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទដ៏ជាក់លាក់មួយ ដែលមានលក្ខណៈប្រទាក់ក្រឡា និងសមស្របទៅនឹងបរិយាកាសសង្គមសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទរបស់នាយកដ្ឋាន រយៈពេល ៥ ឆ្នាំបានរៀបចំឡើងជាឯកសារយោង និងតម្រង់ទិសដៅសម្រាប់អនុវត្តឱ្យសម្រេចបាននូវគោលដៅ គោលបំណង និងសកម្មភាពទាំងឡាយសម្រាប់រយៈពេល ៥ ឆ្នាំខាងមុខ។ ផែនការយុទ្ធសាស្ត្រនេះ បានរៀបចំឡើងតាមរយៈការប្រជុំពិភាក្សាក្នុងក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋាន ដោយផ្អែកលើយុទ្ធសាស្ត្ររបស់ក្រសួងអភិវឌ្ឍន៍ជនបទ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល។

ផែនការយុទ្ធសាស្ត្រ បានរៀបចំឡើងជា ៥ ផ្នែកសំខាន់ៗ ដោយផ្តោតទៅលើការងារស្នូលចំនួន ៤ គឺ ការងារឥណទានជនបទ ការងារសហគ្រាសខ្នាតមីក្រូ និងខ្នាតតូច ការងាររកទីផ្សារ និងការអភិវឌ្ឍជនបទតាមរយៈវិធីសាស្ត្រចលនាភូមិថ្មី។ ផែនការនេះ ក៏បានបង្ហាញពីយុទ្ធសាស្ត្រគន្លឹះក្នុងការពង្រឹងសមត្ថភាពមន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាភ្នាក់ងារផ្តល់សេវាជូនប្រជាពលរដ្ឋនៅជនបទ ស្របតាមគោលការណ៍ នីតិវិធី និងឯកសារគតិយុត្តនានា ដែលរៀបចំឡើងដោយនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ។ ទន្ទឹមនឹងនេះ នាយកដ្ឋាននឹងរៀបចំនូវឯកសារមូលដ្ឋានគតិយុត្តចាំបាច់មួយចំនួនបន្ថែម ដើម្បីគាំទ្រ និងពង្រឹងប្រព័ន្ធប្រតិបត្តិការក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋនៅជនបទឱ្យកាន់តែល្អប្រសើរឡើងស្របតាមស្ថានភាពសេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់ស្តែង។ ផ្អែកលើស្ថានភាពនាពេលបច្ចុប្បន្ន នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ កំពុងជួបប្រទះនូវបញ្ហាប្រឈមលើផ្នែកបច្ចេកទេស និងថវិកា សម្រាប់ប្រតិបត្តិការផ្តល់សេវាជូនប្រជាពលរដ្ឋនៅជនបទ។ ដូច្នេះការចូលរួមគាំទ្រពីគ្រប់ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ជាធនធានដ៏ចាំបាច់បំផុតដែលមិនអាចខ្វះបាន។ ផែនការយុទ្ធសាស្ត្រ ក៏បានចែងពីយុទ្ធសាស្ត្រស្វែងរកជំនួយបច្ចេកទេស និងហិរញ្ញប្បទាន ព្រមទាំងយុទ្ធសាស្ត្រពង្រឹងប្រព័ន្ធតាមដាន និងវាយតម្លៃផងដែរ។

## ២. ចក្ខុវិស័យ

ចក្ខុវិស័យរបស់នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ សំដៅជំរុញកំណើនសេដ្ឋកិច្ចនៅជនបទ តាមរយៈការសម្របសម្រួល និងគាំទ្រផ្នែកបច្ចេកទេស ក្នុងការផ្តល់ឥណទានជូនប្រជាពលរដ្ឋនៅជនបទ សម្រាប់បង្កើត និងពង្រីកមុខរបរ ឬអាជីវកម្មខ្នាតតូច ព្រមទាំងបង្កើតជាបណ្តាញផ្សារភ្ជាប់ទំនាក់ទំនងរវាងផលិតករ និងទីផ្សារ។

## ៣. គោលបំណង

ផែនការយុទ្ធសាស្ត្ររបស់នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ រៀបចំឡើងដើម្បីចូលរួមចំណែកអនុវត្តគោលនយោបាយជាយុទ្ធសាស្ត្ររបស់ក្រសួង និងរាជរដ្ឋាភិបាល ជាពិសេសពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋនៅជនបទ សំដៅជំរុញកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រនៅជនបទ ឱ្យកាន់តែល្អប្រសើរឡើង។

## ៤. យុទ្ធសាស្ត្រសំខាន់ៗរបស់នាយកដ្ឋាន

### ៤.១ ការពង្រឹងសមត្ថភាពមន្ត្រី

ការពង្រឹងសមត្ថភាពមន្ត្រី សំដៅលើការផ្តល់ការបណ្តុះបណ្តាលឱ្យស្របទៅនឹងតម្រូវការជំនាញនិងចំណេះដឹងជាក់ស្តែង តាមរយៈការបណ្តុះបណ្តាលក្នុង និងក្រៅប្រទេស ការផ្លាស់ប្តូរបទពិសោធន៍ និងការលើកទឹកចិត្តឱ្យមានការស្រាវជ្រាវផ្សេងៗ ជូនដល់មន្ត្រីនាយកដ្ឋាន និងមន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៃមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត។

ដើម្បីសម្រេចបាននូវការពង្រឹងសមត្ថភាពមន្ត្រី ត្រូវផ្អែកលើយុទ្ធសាស្ត្រ ដូចខាងក្រោម ÷

1. បញ្ជូនមន្ត្រីឱ្យទៅចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែង ក្នុងនិងក្រៅប្រទេស
   - សិក្សាអំពីតម្រូវការវគ្គបណ្តុះបណ្តាលជាក់ស្តែង
   - ស្វែងរកគ្រឹះស្ថាន ឬស្ថាប័នបណ្តុះបណ្តាលឱ្យត្រូវទៅតាមតម្រូវការជំនាញជាក់ស្តែងរបស់មន្ត្រី
   - ស្វែងរកកិច្ចសហប្រតិបត្តិការគាំទ្រផ្នែកហិរញ្ញវត្ថុ និងអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាល
   - ជ្រើសរើស និងបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាល។
2. ធ្វើការផ្លាស់ប្តូរបទពិសោធន៍រវាងមន្ត្រីក្នុងនាយកដ្ឋាន និងជាមួយមន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៃមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងស្ថាប័នផ្សេងៗ
   - រៀបចំសិក្ខាសាលា
   - ប្រជុំផ្សព្វផ្សាយចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពីការបណ្តុះបណ្តាល។
3. លើកទឹកចិត្តឱ្យមន្ត្រីបន្តសិក្សាស្រាវជ្រាវពីចំណេះដឹងថ្មីៗបន្ថែមដោយខ្លួនឯង
   - បង្កលក្ខណៈងាយស្រួលសម្រាប់ការសិក្សាស្រាវជ្រាវ
   - ផ្តល់រង្វាន់លើកទឹកចិត្តដូចជា ប័ណ្ណសរសើរ ឬវត្ថុអនុស្សាវរីយ៍។

### ៤.២. ការសិក្សាស្រាវជ្រាវស្ថានភាពសេដ្ឋកិច្ចសង្គមជនបទ

1. ជ្រើសរើសតំបន់គោលដៅ
2. ប្រមូលព័ត៌មានទូទៅ
3. រៀបចំវិធីសាស្ត្រស្រាវជ្រាវ
4. អនុវត្តវិធីសាស្ត្រស្រាវជ្រាវ
5. បោះពុម្ព និងផ្សព្វផ្សាយ

## ៤.៣. ការរៀបចំឯកសារគោលការណ៍ នីតិវិធី និងឯកសារគតិយុត្តតាមវិស័យ

### ១. ការងារឥណទាន

អភិវឌ្ឍន៍គោលការណ៍និងនីតិវិធីផ្សេងៗរបស់ឥណទានជនបទ ឲ្យស្របទៅតាមការប្រកួតប្រជែងទីផ្សារ និងតម្រូវការជាក់ស្តែង ក្នុងនោះមាន÷

1. គោលនយោបាយឥណទានជនបទ
   - គោលបំណងឯកសារគោលនយោបាយឥណទានជនបទរៀបចំឡើងដើម្បីឲ្យគម្រោងឥណទានជនបទរាជធានីខេត្តមានដំណើរការប្រកបដោយនិរន្តរភាពនិងប្រជាជនអាចទទួលបានឥណទានប្រើប្រាស់និងមានការកើនឡើងនូវកម្រិតជីវភាពរស់នៅ។
   - ខ្លឹមសាររួមគោលនយោបាយឥណទានជនបទនេះបង្កើតឡើងឲ្យស្របតាមច្បាប់ ដើម្បីអោយមានបទដ្ឋានច្បាស់លាស់មួយសម្រាប់អោយអ្នកគ្រប់គ្រងនិងប្រតិបត្តិករអនុវត្តផ្ទៃក្នុង និងសម្រាប់អនុវត្តជាមួយអតិថិជនប្រកបដោយតម្លាភាព និងអាចកាត់បន្ថយបាននូវហានិភ័យនានាដែលអាចកើតឡើង។
2. គោលការណ៍គ្រប់គ្រងធនធានមនុស្ស សម្រាប់ឥណទានជនបទ
   - គោលបំណងដើម្បីបង្កើនប្រសិទ្ធភាពការអនុវត្តគម្រោងឥណទានឲ្យមាននិរន្តរភាព។
   - ខ្លឹមសាររួមចែងអំពីនីតិវិធីរដ្ឋបាល សម្រាប់ការគ្រប់គ្រង និងពង្រឹងសមត្ថភាពមន្ត្រីរបស់គម្រោងឥណទានជនបទ
3. គោលការណ៍ និងនីតិវិធីឥណទានជនបទ
   - គោលបំណងដើម្បីពង្រឹងការគ្រប់គ្រង និងការអនុវត្តគម្រោងឥណទានឲ្យមានប្រសិទ្ធភាពខ្ពស់ប្រកបដោយចិរភាពយូរអង្វែង។
   - ខ្លឹមសាររួមនិយាយអំពីសេចក្តីណែនាំ គោលការណ៍ បទបញ្ញត្តិ និងទម្រង់បែបបទឥណទានផ្សេងៗ សម្រាប់តម្រង់ទិសការអនុវត្តគម្រោងឥណទានជនបទ។
4. គោលការណ៍ និងនីតិវិធីឥណទានមិនមែនសាច់ប្រាក់
   - គោលបំណងដើម្បីពង្រឹងការគ្រប់គ្រង និងការអនុវត្តកម្មវិធីឥណទានមិនមែនសាច់ប្រាក់ឲ្យមានប្រសិទ្ធភាពខ្ពស់ប្រកបដោយចិរភាពយូរអង្វែង។
   - ខ្លឹមសាររួមនិយាយអំពីសេចក្តីណែនាំ បទបញ្ញត្តិ និងទម្រង់បែបបទផ្សេងៗ សម្រាប់តម្រង់ទិស ការប្រតិបត្តិកម្មវិធីឥណទានមិនមែនសាច់ប្រាក់ ។

5. **នីតិវិធីគណនេយ្យ**
    - ➢ គោលបំណងដើម្បីជាការណែនាំដល់គណនេយ្យករហិរញ្ញវត្ថុអនុវត្តឱ្យមានតម្លាភាពក្នុងការគ្រប់គ្រងសាច់ប្រាក់របស់គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទ។
    - ➢ ខ្លឹមសាររួមនិយាយអំពីរបៀបរបប លំហូរសាច់ប្រាក់ ការរក្សាសាច់ប្រាក់ការរក្សាទុកឯកសារ លេខគណនី បែបបទចំណូល និងចំណាយ និងទម្រង់បែបបទផ្សេងៗ ។

## ២. ការងារសហគ្រាសខ្នាតតូច

1. គោលនយោបាយអភិវឌ្ឍន៍សហគ្រាសជនបទ
    - ➢ គោលបំណងដើម្បីលើកកម្ពស់ជីវភាពប្រជាពលរដ្ឋនៅតាមជនបទ តាមរយៈការបង្កើតការងារ។
    - ➢ ខ្លឹមសាររួមគឺ ជាការផ្តល់លទ្ធភាពដល់ សិប្បករ ផលិតករ ពាណិជ្ជករ អាជីវករបង្កើតមុខរបរ បង្កើនលទ្ធភាពផលិត ស្វែងរកទីផ្សារសម្រាប់ផលិតផលឱ្យមានភាពទូលំទូលាយ ផ្តល់ភាពងាយស្រួលក្នុងការទទួលបាននូវហិរញ្ញវត្ថុ ក្នុងវិស័យសហគ្រាសខ្នាតតូច និងសហគ្រាសខ្នាតមីក្រូ។
2. គោលការណ៍ស្តីពីការបង្កើតសហគ្រាសជនបទ
    - ➢ គោលបំណងដើម្បីបង្កើតសហគ្រាសជនបទ ក្នុងបរិយាកាសមួយប្រកបដោយភាពអនុគ្រោះ។
    - ➢ ខ្លឹមសាររួមចែងអំពីលក្ខខណ្ឌ និងដំណើរការនានា សម្រាប់បង្កើតសហគ្រាស។
3. គោលការណ៍ស្តីពីការគ្រប់គ្រងសហគ្រាសជនបទ
    - ➢ គោលបំណងដើម្បីកែតម្រូវប្រព័ន្ធគ្រប់គ្រងពីមុនដែលមានភាពខ្វះខាតឱ្យមានលក្ខណៈស្តង់ដារ
    - ➢ ខ្លឹមសាររួមចែងអំពីរចនាសម្ព័ន្ធនៃការគ្រប់គ្រងសហគ្រាសខ្នាតតូច និងខ្នាតមីក្រូដូចជា ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធគ្រប់គ្រងខ្សែសង្វាក់ផលិតកម្ម និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្នុងសហគ្រាស។
4. ឯកសារបណ្តុះបណ្តាលផ្នែកសហគ្រាសជនបទ
    - ➢ មេរៀនបណ្តុះបណ្តាលមានដូចខាងក្រោម៖
        - បច្ចេកទេសសាងសង់ឡជីវឧស្ម័ន
        - បច្ចេកទេសផលិតចង្ក្រាននាងកង្រី
        - បច្ចេកទេសផលិតធ្យូងពីរុក្ខជាតិ(Mimosapigra )
        - បច្ចេកទេសផលិតធ្យូងសេដ្ឋកិច្ច (កាកសំណល់រុក្ខជាតិ)

- បច្ចេកទេសផលិតស្ករត្នោតម្សៅ
- បច្ចេកទេសត្បាញស្លូត្រ
- បច្ចេកទេសត្បាញក្រមា
- គំនិតផ្តួចផ្តើម ក្នុងការបង្កើតអាជីវកម្មជនបទ

5. **នីតិវិធីក្នុងកិច្ចដំណើរការចងក្រង និងគ្រប់គ្រងសមាគមសហគ្រាសជនបទ**

**៣. ការងារទីផ្សារជនបទ**

ឯកសារការងារទីផ្សារជនបទ បានផ្តោតលើ÷

1. គោលនយោបាយអភិវឌ្ឍន៍ផ្សារជនបទ
   - ➢ គោលបំណងដើម្បីតម្រង់ទិសដល់ក្រុមការងាររកទីផ្សារ និងផលិតករនៅជនបទ ធ្វើជាមូលដ្ឋានក្នុងការអនុវត្តការងារ ក៏ដូចជាការលើកកម្ពស់ផលិតផល និងកសិផលពីជនបទមកកាន់ទីផ្សារ ដើម្បីឆ្លើយតបទៅនឹងតម្រូវការ និងការប្រកួតប្រជែងទីផ្សារក្នុង និងក្រៅប្រទេស។
   - ➢ ខ្លឹមសារសំខាន់ៗនៃឯកសារនេះផ្តោតលើការរៀបចំផ្សារ ការកែលម្អផ្សារជនបទ ការការពារតម្លៃកសិផល និងផលិតផលរបស់ផលិតករ។
2. យន្តការនៃការគ្រប់គ្រងផ្សារជនបទ
   - ➢ គោលបំណង ដើម្បីធានាឱ្យផ្សារជនបទមានដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព
   - ➢ ខ្លឹមសាររួមផ្តោតការយកចិត្តទុកដាក់លើការរៀបចំរចនាសម្ព័ន្ធ និងការកំណត់អំពីតួនាទី និងភារកិច្ចយ៉ាងជាក់លាក់នៃសមាសភាពគណៈកម្មាធិការគ្រប់គ្រងផ្សារជនបទ។
3. គោលការណ៍នៃការរៀបចំ និងសាងសង់ផ្សារជនបទ
   - ➢ គោលបំណង ដើម្បីធានាការផ្តល់សេវា បរិស្ថានល្អ និងមានសណ្តាប់ធ្នាប់ល្អ
   - ➢ ខ្លឹមសាររួមផ្តោតសំខាន់លើការកំណត់លក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសទីតាំង គំនូសប្លង់ និងការសាងសង់ផ្សារឱ្យមានស្តង់ដាររួម។
4. ឯកសារបណ្តុះបណ្តាលផ្នែកទីផ្សារជនបទ

   ឯកសារបណ្តុះបណ្តាលនេះ រៀបចំចងក្រងចំនួន ៥ប្រធានបទ ដូចខាងក្រោម÷
   - ទស្សនទានមូលដ្ឋានទីផ្សារជនបទ
   - វិធីសាស្ត្រចរចារតម្លៃផលិតផល
   - វិធីសាស្ត្រប្រកួតប្រជែងទីផ្សារ

- វិធីសាស្ត្រលក់ផលិតផល
- វិធីសាស្ត្រស្រាវជ្រាវតម្លៃទីផ្សារផលិតផល

## ៤.៤. ពង្រឹងប្រព័ន្ធប្រតិបត្តិការក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ

### ១. ផ្នែកឥណទានជនបទ

1. ពង្រឹងប្រព័ន្ធគ្រប់គ្រង និងពង្រីកតំបន់ប្រតិបត្តិការគម្រោងឥណទានជនបទ
2. ជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋនៅតាមជនបទក្នុងការបង្កើតក្រុមសន្សំប្រាក់ និងប្រើប្រាស់ឥណទាននៅក្នុងសហគមន៍
3. បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ឥណទានសម្រាប់ប្រជាពលរដ្ឋនៅតាមជនបទ
4. សម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋានក្នុងកិច្ចការពាក់ពន្ធ័ទៅនឹងដំណើរការឥណទានជនបទ
5. ពង្រឹងកម្មវិធីឥណទានជនបទមិនមែនសាច់ប្រាក់។

### ២. ផ្នែកសហគ្រាសខ្នាតតូច

1. ការផ្តល់សេវាបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈ និងការគ្រប់គ្រងអាជីវកម្មដល់ប្រជាពលរដ្ឋនៅតាមជនបទ ឲ្យមានលទ្ធភាពក្នុងការបង្កើតមុខរបរ និងការងារផ្សេងៗ
   - សិក្សាអំពីតម្រូវការបណ្តុះបណ្តាល
   - រៀបចំផែនការវគ្គបណ្តុះបណ្តាល
   - អនុវត្តវគ្គបណ្តុះបណ្តាល
   - តាមដាន និងវាយតម្លៃការបណ្តុះបណ្តាល
2. ផ្តល់សេវាប្រឹក្សាក្នុងការបង្កើត និងគ្រប់គ្រងអាជីវកម្មដល់ប្រជាពលរដ្ឋនៅតាមជនបទ
   - សិក្សាអំពីតម្រូវការសេវាប្រឹក្សាផ្សេងៗ
   - កំណត់ប្រភេទសេវាប្រឹក្សា
   - រៀបចំវិធីសាស្ត្រក្នុងការផ្តល់សេវាប្រឹក្សា
   - ផ្សព្វផ្សាយអំពីកម្មវិធីផ្តល់សេវាប្រឹក្សាក្នុងការបង្កើត និងគ្រប់គ្រងអាជីវកម្មដល់ប្រជាពលរដ្ឋនៅតាមជនបទ
3. ស្រាវជ្រាវព័ត៌មានទិន្នន័យថ្មីៗ សម្រាប់លើកគម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ និងខ្នាតតូច
   - សិក្សាស្រាវជ្រាវអំពីសក្តានុពលដែលមានក្នុងសហគមន៍ជនបទដើម្បីបង្កើតនិងពង្រីកសហគ្រាសខ្នាតតូចសិប្បកម្ម និងអាជីវកម្ម

- វិភាគទិន្នន័យសក្តានុពលដែលប្រមូលបាន ដើម្បីលើកគម្រោងសម្រាប់រយៈពេលវែង មធ្យម និងខ្លី
- ផ្សព្វផ្សាយ និងអនុវត្ត។

**៣. ផ្នែកទីផ្សារជនបទ**

1. ផ្តល់ជំនាញផ្នែកទីផ្សារដល់កសិករអាជីវករ សិប្បករ ពាណិជ្ជករនៅតាមជនបទ
   - សិក្សាស្រាវជ្រាវតម្រូវការវគ្គបណ្តុះបណ្តាលលើផ្នែកទីផ្សារ
   - រៀបចំផែនការវគ្គបណ្តុះបណ្តាល
   - អនុវត្តវគ្គបណ្តុះបណ្តាល
   - តាមដាននិងវាយតម្លៃការបណ្តុះបណ្តាល។
2. សិក្សាស្រាវជ្រាវតម្រូវការនិងការផ្គត់ផ្គង់ទីផ្សារកសិផលនិងផលិតផលនៅលើទីផ្សារជាតិនិងអន្តរជាតិ
   - ប្រមូលនិងស្រង់ទិន្នន័យអំពីតម្រូវការផ្គត់ផ្គង់និងតម្លៃកសិផលនិងផលិតផលនៅលើទីផ្សារជាតិ និងអន្តរជាតិ
   - សិក្សាស្វែងរកកាលានុវត្តភាពនិងហានិភ័យនៃទីផ្សារកសិផលនិងផលិតផល
   - រៀបចំអនុសាសន៍ដល់កសិករសិប្បករអាជីវករពាណិជ្ជករនៅតាមជនបទក្នុងការផលិតនិងផ្គត់ផ្គង់កសិផលនិងផលិតផលឲ្យស្របទៅតាមតម្រូវការទីផ្សារ។
3. ផ្សព្វផ្សាយអំពីតម្រូវការការផ្គត់ផ្គង់និងតម្លៃកសិផលនិងផលិតផលនៅលើទីផ្សារជាតិនិងអន្តរជាតិដល់កសិករសិប្បករអាជីវករពាណិជ្ជករនៅតាមជនបទ
   - ផ្តល់ព័ត៌មានអំពីតម្រូវការការផ្គត់ផ្គង់និងតម្លៃតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសិក្ខាសាលាប្រជុំ
   - បង្កើតតារាងព័ត៌មានទីផ្សារកសិផលផលិតផលនិងតម្លៃមធ្យោបាយផលិតកម្មដែលជាតម្រូវការចាំបាច់តាមសហគមន៍ជនបទ។
4. សម្របសម្រួលកសិផលនិងផលិតផលនៅតាមជនបទឱ្យចូលដល់ទីផ្សារជាតិនិងអន្តរជាតិ
   - រៀបចំពិព័ណ៌កសិផលនិងផលិតផលៈ សហការ ឬបង្កើតយន្តការទំនាក់ទំនងជាមួយក្រសួងពាណិជ្ជកម្ម ស្តង់ពិព័ណ៌សម្រាប់កសិករ
   - ផ្តល់សេវាប្រឹក្សាផ្នែកទីផ្សារកសិផលនិងផលិតផល
   - ផ្សព្វផ្សាយកសិផល និងផលិតផលតាមប្រព័ន្ធព័ត៌មាន
   - រៀបចំសិក្ខាសាលាផ្សព្វផ្សាយកសិផល និងផលិតផល។

5. ជំរុញតម្លៃកសិផលនិងផលិតផលរបស់កសិករសិប្បករអាជីវករពាណិជ្ជករនៅតាមជនបទ
   - ជំរុញការបង្កើនគុណភាពកសិផល និងផលិតផល
   - បង្កើតស្តង់ដារផលិតផលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
   - ចងក្រងជាសមាគម និងសហគមន៍កសិករ សិប្បករ អាជីវករពាណិជ្ជករ ដើម្បីការពារតម្លៃកសិផល និងផលិតផលឲ្យបានសមស្របតាមតម្លៃទីផ្សារជាក់ស្តែង។
6. រៀបចំបង្កើតផ្សារជនបទ
   - សិក្សាស្រាវជ្រាវអំពីសេដ្ឋកិច្ចសង្គមជនបទ ដើម្បីកំណត់អំពីសក្តានុពលក្នុងការបង្កើតផ្សារជនបទ
   - សិក្សាលើសំណង់ផ្សារជនបទ
   - សាងសង់ផ្សារជនបទ។

### ៤.៥. រៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រចលនាភូមិថ្មី

1. រៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជាតាមវិធីសាស្ត្រចលនាភូមិថ្មីឲ្យមានសង្គតិភាពជាមួយគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
2. រៀបចំគម្រោង និងជ្រើសរើសទីតាំងភូមិសាស្ត្រសមស្រប សម្រាប់ធ្វើការអនុវត្តសាកល្បងនូវគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រ ចលនាភូមិថ្មី
3. សម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍស្របតាមគោលនយោបាយ ផែនការ និងទីតាំងភូមិសាស្ត្រដែលបានជ្រើសរើស
4. ផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកទឹកចិត្តឲ្យប្រជាពលរដ្ឋស្វែងយល់អំពីទស្សនៈរបស់ចលនាភូមិថ្មី និងចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រចលនាភូមិថ្មី
5. កៀរគរថវិកា និងទាក់ទាញឲ្យមានការចូលរួមវិនិយោគពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅក្នុងការអនុវត្តគម្រោង។

### ៤.៦. ការស្វែងរកហិរញ្ញប្បទាន និងជំនួយបច្ចេកទេស

1. សម្របសម្រួលជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ អង្គការជាតិអន្តរជាតិនិងសហគមន៍ដើម្បីឲ្យប្រជាពលរដ្ឋនៅតាមជនបទទទួលបានប្រាក់កម្ចីក្នុងអត្រាការប្រាក់ទាប
2. ផ្សព្វផ្សាយពីព័ត៌មានវឌ្ឍនភាពគម្រោងដល់ស្ថាប័នជាដៃគូគ្រឹះស្ថាននិងម្ចាស់ជំនួយនានា

3. បង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិអន្តរជាតិ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីអភិវឌ្ឍន៍ឥណទានជនបទ សហគ្រាសខ្នាតមីក្រូ និងខ្នាតតូចនិងទីផ្សារជនបទឱ្យមានភាពរីកចម្រើន
4. ទំនាក់ទំនងជាមួយស្ថាប័នជាតិ អន្តរជាតិ វិស័យឯកជននិងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីទទួលបានហិរញ្ញប្បទាន និងជំនួយបច្ចេកទេស។

## ៤.៧. ពង្រឹងការតាមដាន និងវាយតម្លៃ

1. បង្កើតក្រុមបច្ចេកទេសតាមដាន និងវាយតម្លៃ
2. យន្តការតាមដាន និងវាយតម្លៃ
3. សិក្សាពីចំណុចខ្លាំង និងចំណុចខ្សោយ
4. ការផ្តល់អនុសាសន៍។

## ៥.តារាងផែនការសកម្មភាព

| ល-រ | | សកម្មភាព | ២០១៤ | | | | ២០១៥ | | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ | ១ | ២ | ៣ | ៤ |
| I | ការពង្រឹងសមត្ថភាពមន្ត្រី | | | | | | | | | | | | | | | | | | | | | |
| | ១ | ការបញ្ជូនមន្ត្រីចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាលរយៈពេលខ្លី មធ្យម និងវែងក្នុង និងក្រៅប្រទេស | | | | | | | | | | | | | | | | | | | | |
| | ១-១ | សិក្សាអំពីតម្រូវការវគ្គបណ្តុះបណ្តាលជាក់ស្តែង | | | | | | | | | | | | | | | | | | | | |
| | ១-២ | ស្វែងរកគ្រឹះស្ថាន ឬស្ថាប័នបណ្តុះបណ្តាលឱ្យត្រូវទៅតាមតម្រូវការជំនាញជាក់ស្តែងរបស់មន្ត្រី | | | | | | | | | | | | | | | | | | | | |
| | ១-៣ | ស្វែងរកកិច្ចសហប្រតិបត្តិការគាំទ្រផ្នែកហិរញ្ញវត្ថុ និងអាហារូបករណ៍សម្រាប់ការបណ្តុះបណ្តាល | | | | | | | | | | | | | | | | | | | | |
| | ១-៤ | ជ្រើសរើស និងបញ្ជូនមន្ត្រីទៅបណ្តុះបណ្តាល | | | | | | | | | | | | | | | | | | | | |
| | ២ | ធ្វើការផ្លាស់ប្តូរបទពិសោធន៍រវាងមន្ត្រីក្នុងនាយកដ្ឋាន និងជាមួយមន្ត្រីការិយាល័យអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនៃមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី ខេត្ត | | | | | | | | | | | | | | | | | | | | |
| | ២-១ | រៀបចំសិក្ខាសាលា | | | | | | | | | | | | | | | | | | | | |
| | ២-២ | ប្រជុំផ្សព្វផ្សាយចំណេះដឹង និងបទពិសោធន៍ដែលទទួលបានពីការបណ្តុះបណ្តាល | | | | | | | | | | | | | | | | | | | | |
| | ៣ | លើកទឹកចិត្តឱ្យមន្ត្រីបន្តការសិក្សាស្រាវជ្រាវពីចំណេះដឹងថ្មីៗបន្ថែម | | | | | | | | | | | | | | | | | | | | |

| | | |
|---|---|---|
| | | ដោយខ្លួនឯង |
| | ៣-១ | បង្កលក្ខណៈងាយស្រួលសម្រាប់ការសិក្សាស្រាវជ្រាវ |
| | ៣-២ | ផ្តល់រង្វាន់លើកទឹកចិត្តដូចជា បំណ្ណសរសើរ ឬវត្ថុអនុស្សាវរីយ៍ |
| II | **ការសិក្សាស្រាវជ្រាវស្ថានភាពសេដ្ឋកិច្ចសង្គមជនបទ** | |
| | ១ | ជ្រើសរើសតំបន់គោលដៅ |
| | ២ | ប្រមូលព័ត៌មានទូទៅ |
| | ៣ | រៀបចំវិធីសាស្ត្រស្រាវជ្រាវ |
| | ៤ | អនុវត្តន៍វិធីសាស្ត្រស្រាវជ្រាវ |
| | ៥ | បោះពុម្ព និងផ្សព្វផ្សាយ |
| III | **រៀបចំឯកសារគោលការណ៍ នីតិវិធី និងឯកសារគតិយុត្តិតាមវិស័យ** | |
| | **១** | **ការងារឥណទាន** |
| | ១-១ | គោលនយោបាយឥណទានជនបទ |
| | ១-២ | គោលការណ៍គ្រប់គ្រងធនធានមនុស្ស សម្រាប់ឥណទានជនបទ |
| | ១-៣ | គោលការណ៍ និងនីតិវិធីឥណទានសាច់ប្រាក់ |
| | ១-៤ | គោលការណ៍ និងនីតិវិធីឥណទានមិនមែនសាច់ប្រាក់ |
| | ១-៥ | នីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់គម្រោងឥណទានជនបទ |
| | **២** | **ការងារសហគ្រាសខ្នាតតូច** |
| | ២-១ | គោលនយោបាយអភិវឌ្ឍន៍សហគ្រាសជនបទ |
| | ២-២ | គោលការណ៍ស្តីពីការបង្កើតសហគ្រាសជនបទ |
| | ២-៣ | គោលការណ៍ស្តីពីការគ្រប់គ្រងសហគ្រាសជនបទ |

| | | |
|---|---|---|
| | ២-៤ | ឯកសារបណ្តុះបណ្តាលផ្នែកសហគ្រាសជនបទ |
| | ២-៥ | នីតិវិធីក្នុងកិច្ចដំណើរការចងក្រងនិងគ្រប់គ្រងសមាគមសហគ្រាសជនបទ |
| | ៣ | **ការងារទីផ្សារជនបទ** |
| | ៣-១ | គោលនយោបាយអភិវឌ្ឍន៍ផ្សារជនបទ |
| | ៣-២ | យន្តការនៃការគ្រប់គ្រងផ្សារជនបទ |
| | ៣-៣ | គោលការណ៍នៃការរៀបចំផ្សារជនបទ |
| | ៣-៤ | ឯកសារបណ្តុះបណ្តាលផ្នែកទីផ្សារជនបទ |
| IV | **ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងប្រតិបត្តិការផ្តល់សេវាជូនប្រជាពលរដ្ឋ** | |
| | ១ | **ផ្នែកឥណទានជនបទ** |
| | ១-១ | ពង្រឹងប្រព័ន្ធគ្រប់គ្រង និងពង្រីកតំបន់ប្រតិបត្តិការគម្រោងឥណទានជនបទ |
| | ១-២ | ជំរុញលើកទឹកចិត្តដល់ប្រជាពលរដ្ឋនៅតាមជនបទក្នុងការបង្កើតក្រុមសន្សំប្រាក់និងប្រើប្រាស់ឥណទាននៅក្នុងសហគមន៍ |
| | ១-៣ | បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ឥណទានសម្រាប់ប្រជាពលរដ្ឋនៅតាមជនបទ |
| | ១-៤ | សម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋានក្នុងកិច្ចការពាក់ពន្ធ័ទៅនឹងដំណើការឥណទានជនបទ |
| | ១-៥ | ពង្រឹងកម្មវិធីឥណទានជនបទមិនមែនសាច់ប្រាក់ដូចជាធនាគារស្រូវធនាគារគោក្របី |
| | ២ | **ផ្នែកសហគ្រាសខ្នាតតូច** |

| | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២-១ | ការផ្ដល់សេវាបណ្ដុះបណ្ដាលជំនាញបច្ចេកទេសវិជ្ជាជីវៈ និងការគ្រប់គ្រងអាជីវកម្មដល់ប្រជាពលរដ្ឋនៅតាមជនបទឱ្យមានលទ្ធភាពក្នុងការបង្កើតមុខរបរ និងការងារផ្សេងៗ | | | | | | | | | | | | | | | | | | | | |
| | ២-១-១ | សិក្សាអំពីតម្រូវការបណ្ដុះបណ្ដាល | | | | | | | | | | | | | | | | | | | | |
| | ២-១-២ | រៀបចំផែនការវគ្គបណ្ដុះបណ្ដាល | | | | | | | | | | | | | | | | | | | | |
| | ២-១-៣ | អនុវត្តន៍វគ្គបណ្ដុះបណ្ដាល | | | | | | | | | | | | | | | | | | | | |
| | ២-១-៤ | តាមដាន និងវាយតម្លៃការបណ្ដុះបណ្ដាល | | | | | | | | | | | | | | | | | | | | |
| | ២-២ | ផ្ដល់សេវាប្រឹក្សាក្នុងការបង្កើត និងគ្រប់គ្រងអាជីវកម្មដល់ប្រជាពលរដ្ឋនៅតាមជនបទ | | | | | | | | | | | | | | | | | | | | |
| | ២-២-១ | សិក្សាអំពីតម្រូវការសេវាប្រឹក្សាផ្សេងៗ | | | | | | | | | | | | | | | | | | | | |
| | ២-២-២ | កំណត់ប្រភេទសេវាប្រឹក្សា | | | | | | | | | | | | | | | | | | | | |
| | ២-២-៣ | រៀបចំវិធីសាស្ត្រក្នុងការផ្ដល់សេវាប្រឹក្សា | | | | | | | | | | | | | | | | | | | | |
| | ២-២-៤ | ផ្សព្វផ្សាយអំពីកម្មវិធីផ្ដល់សេវាប្រឹក្សាក្នុងការបង្កើត និងគ្រប់គ្រងអាជីវកម្មដល់ប្រជាពលរដ្ឋនៅតាមជនបទ | | | | | | | | | | | | | | | | | | | | |
| | ២-៣ | ស្រាវជ្រាវព័ត៌មានទិន្នន័យថ្មីៗ សម្រាប់លើកគម្រោងអភិវឌ្ឍន៍សហគ្រាសខ្នាតមីក្រូ និងខ្នាតតូច | | | | | | | | | | | | | | | | | | | | |
| | ២-៣-១ | សិក្សាស្រាវជ្រាវអំពីសក្ដានុពលដែលមានក្នុងសហគមន៍ជនបទ ដើម្បីបង្កើត និងពង្រីកសហគ្រាសខ្នាតតូចសិប្បកម្ម និងអាជីវកម្ម | | | | | | | | | | | | | | | | | | | | |
| | ២-៣-២ | វិភាគទិន្នន័យសក្ដានុពលដែលប្រមូលបានដើម្បីលើកគម្រោងសម្រាប់រយៈពេលវែង មធ្យម និងខ្លី | | | | | | | | | | | | | | | | | | | | |

| | | |
|---|---|---|
| | ២-៣-៣ | ផ្សព្វផ្សាយ និងអនុវត្ត |
| | ៣ | **ផ្នែកទីផ្សារជនបទ** |
| | ៣-១ | ផ្តល់ជំនាញផ្នែកទីផ្សារដល់កសិករអាជីវករ សិប្បករ ពាណិជ្ជករនៅតាមជនបទ |
| | ៣-១-១ | សិក្សាស្រាវជ្រាវតម្រូវការវគ្គបណ្តុះបណ្តាលលើផ្នែកទីផ្សារ |
| | ៣-១-២ | រៀបចំផែនការវគ្គបណ្តុះបណ្តាល |
| | ៣-១-៣ | អនុវត្តន៍វគ្គបណ្តុះបណ្តាល |
| | ៣-១-៤ | តាមដាននិងវាយតម្លៃការបណ្តុះបណ្តាល |
| | ៣-២ | សិក្សាស្រាវជ្រាវតម្រូវការ និងការផ្គត់ផ្គង់ទីផ្សារកសិផលនិងផលិតផលនៅលើទីផ្សារជាតិនិងអន្តរជាតិ |
| | ៣-២-១ | ប្រមូលនិងស្រង់ទិន្នន័យអំពីតម្រូវការផ្គត់ផ្គង់និងតម្លៃកសិផលនិងផលិតផលនៅលើទីផ្សារជាតិ និងអន្តរជាតិ |
| | ៣-២-២ | សិក្សាស្វែងរកកាលានុវត្តភាពនិងហានិភ័យនៃទីផ្សារកសិផលនិងផលិតផល |
| | ៣-២-៣ | រៀបចំអនុសាសន៍ដល់កសិករសិប្បករអាជីវករពាណិជ្ជករនៅតាមជនបទក្នុងការផលិតនិងផ្គត់ផ្គង់កសិផលនិងផលិតផលឲ្យស្របទៅតាមតម្រូវការទីផ្សារ |
| | ៣-៣ | ផ្សព្វផ្សាយអំពីតម្រូវការការផ្គត់ផ្គង់និងតម្លៃកសិផលនិងផលិតផលនៅលើទីផ្សារជាតិនិងអន្តរជាតិដល់កសិករសិប្បករអាជីវករពាណិជ្ជករនៅតាមជនបទ |

| | | |
|---|---|---|
| | ៣-៣-១ | ផ្តល់ព័ត៌មានអំពីតម្រូវការការផ្គត់ផ្គង់និងតម្លៃតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានសិក្ខាសាលាប្រជុំ |
| | ៣-៣-២ | បង្កើតតារាងព័ត៌មានទីផ្សារកសិផលផលិតផលនិងតម្លៃមធ្យោបាយផលិតកម្មដែលជាតម្រូវការចាំបាច់តាមសហគមន៍ជនបទ |
| | ៣-៤ | សម្របសម្រួលឱ្យកសិផលនិងផលិតផលនៅតាមជនបទចរាចរចូលដល់ទីផ្សារជាតិនិងអន្តរជាតិ |
| | ៣-៤-១ | រៀបចំពិព័ណ៌កសិផលនិងផលិតផល |
| | ៣-៤-២ | ផ្តល់សេវាប្រឹក្សាផ្នែកទីផ្សារកសិផលនិងផលិតផល |
| | ៣-៤-៣ | ផ្សព្វផ្សាយកសិផល និងផលិតផលតាមប្រព័ន្ធព័ត៌មាន |
| | ៣-៤-៤ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយកសិផល និងផលិតផល |
| | ៣-៥ | ជំរុញតម្លៃកសិផលនិងផលិតផលរបស់កសិករសិប្បករអាជីវករពាណិជ្ជករនៅតាមជនបទ |
| | ៣-៥-១ | ជំរុញការបង្កើនគុណភាពកសិផល និងផលិតផល |
| | ៣-៥-២ | រៀបចំស្តង់ដារផលិតផលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ៣-៥-៣ | ចងក្រងជាសមាគម និងសហគមន៍កសិករ សិប្បករ អាជីវករពាណិជ្ជករ ដើម្បីការពារតម្លៃកសិផល និងផលិតផលឱ្យបានសមស្របតាមតម្លៃទីផ្សារជាក់ស្តែង |
| | ៣-៦ | រៀបចំបង្កើតផ្សារជនបទ |
| | ៣-៦-១ | សិក្សាស្រាវជ្រាវអំពីសេដ្ឋកិច្ចសង្គមជនបទ ដើម្បីកំណត់អំពីសក្តានុពលក្នុងការបង្កើតផ្សារជនបទ |

| | | |
|---|---|---|
| | ៣-៦-២ | សិក្សាលើសំណង់ផ្សារជនបទ |
| | ៣-៦-៣ | សាងសង់ផ្សារជនបទ |
| V | **រៀបចំសម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទតាមវិធីសាស្ត្រចលនាភូមិថ្មី** | |
| | ១ | រៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជាតាមវិធីសាស្ត្រ ចលនាភូមិថ្មីឱ្យមានសង្គតិភាពជាមួយគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល និងគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា |
| | ២ | រៀបចំគម្រោង និងជ្រើសរើសទីតាំងភូមិសាស្ត្រសមស្របសម្រាប់ធ្វើការអនុវត្តសាកល្បងនូវគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រ ចលនាភូមិថ្មី |
| | ៣ | សម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ស្របតាមគោលនយោបាយ ផែនការ និងទីតាំងភូមិសាស្ត្រដែលបានជ្រើសរើស |
| | ៤ | ផ្សព្វផ្សាយព័ត៌មាន ដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋស្វែងយល់អំពីទស្សនៈរបស់ចលនាភូមិថ្មី និងចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រចលនាភូមិថ្មី |
| | ៥ | កៀរគរថវិការ និងទាក់ទាញឱ្យមានការចូលរួមវិនិយោគពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍នៅក្នុងការអនុវត្តគម្រោង |

| | | |
|---|---|---|
| VI | **ការស្វែងរកហិរញ្ញប្បទាន និងជំនួយបច្ចេកទេស** | |
| | ១ | សម្របសម្រួលជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ អង្គការជាតិអន្តរជាតិនិងសហគមន៍ដើម្បីឱ្យប្រជាពលរដ្ឋនៅតាមជនបទទទួលបានប្រាក់កម្ចីក្នុងអត្រាការប្រាក់ទាប |
| | ២ | ផ្សព្វផ្សាយពីព័ត៌មានវឌ្ឍនភាពគម្រោងដល់ស្ថាប័នជាដៃគូគ្រឹះស្ថាននិងម្ចាស់ជំនួយនានា |
| | ៣ | បង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិអន្តរជាតិ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីអភិវឌ្ឍន៍ឥណទានជនបទ សហគ្រាសខ្នាតមីក្រូ និងខ្នាតតូចនិងទីផ្សារជនបទឱ្យមានភាពរីកចម្រើន |
| | ៤ | ទំនាក់ទំនងជាមួយស្ថាប័នជាតិ អន្តរជាតិ វិស័យឯកជននិងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីទទួលបានហិរញ្ញប្បទាន និងជំនួយបច្ចេកទេស |
| VII | **ពង្រឹងការតាមដាន និងវាយតម្លៃ** | |
| | ១ | បង្កើតក្រុមបច្ចេកទេសតាមដាន និងវាយតម្លៃ |
| | ២ | យន្តការតាមដាន និងវាយតម្លៃ |
| | ៣ | សិក្សាពីចំណុចខ្លាំង និងចំណុចខ្សោយ |
| | ៤ | ការផ្ដល់អនុសាសន៍ |

## ៦. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ ២០១៤ - ២០១៨ របស់នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ជាឯកសារគោលដ៏សំខាន់របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការសម្រេចឱ្យបាននូវគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ជាពិសេសការបង្រួមគំលាតរវាងទីក្រុង និងជនបទ តាមរយៈការជំរុញកំណើនសេដ្ឋកិច្ចនៅជនបទ ដូចជាការផ្តល់សេវាឥណទានក្នុងអត្រាការប្រាក់ទាបសមរម្យ ជូនប្រជាពលរដ្ឋក្រីក្រនៅជនបទឱ្យទទួលបាននូវកាលានុវត្តន៍ភាពក្នុងការបង្កើត និងពង្រីកមុខរបរ ឬអាជីវកម្មខ្នាតមីក្រូ និងខ្នាតតូច ព្រមទាំងជួយសម្របសម្រួលបង្កើតជាបណ្តាញផ្សារភ្ជាប់ទំនាក់ទំនងរវាងផលិតករ និង ទីផ្សារដោះដូរផលិតផលនៅទីជនបទ។